ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម

លេខ :.......✓.............ប.ស.ស.

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលពិធីប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ បេឡាជាតិសន្តិសុខសង្គម បានរៀបចំពិធីប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់បេឡាជាតិសន្តិសុខសង្គម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម។ ពិធីប្រជុំបូកសរុបបានពិនិត្យពិភាក្សាអំពីវឌ្ឍនភាពការងារឆ្នាំ២០២២ នៃការអនុវត្តផែនការរបស់ ប.ស.ស. ឆ្នាំ២០២២ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៨-២០២៣ ដោយផ្តោតទៅលើវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅអាទិភាពការងារបន្តឆ្នាំ២០២៣។

### ក. លទ្ធផលការងារសម្រេចបានឆ្នាំ២០២២

គិតត្រឹមឆ្នាំ២០២២ នេះ ប.ស.ស. បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងស្ថាប័នក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសរុប ២១ ៨៣០សហគ្រាស និងមានសមាជិកសរុប ៣ ១២០ ២០៨នាក់ ស្រី ១ ៧៩៨ ៥១០នាក់ ទទួលបានចំណូលភាគទានសរុបក្នុងឆ្នាំ២០២២ នេះ ប្រមាណជា ៧៤០,៤៨ ប៊ីលានរៀល និងចំណាយថវិកាអស់ប្រមាណជា ៣៤៥,៩០ប៊ីលានរៀល លើការផ្តល់តាវកាលិកដល់ជនរងគ្រោះ ផ្នែកហានិភ័យការងារចំនួន ៩ ០៨៣នាក់ ស្រី ៤ ៥៣៩នាក់ និងមានអ្នកចូលប្រើប្រាស់សេវាថែទាំសុខភាពសរុបចំនួន ៣ ០០០ ០៤០ករណី ស្រី ២ ១៩៥ ៣៦៥ករណី។

#### ១- ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជន

❖ ផ្នែកហានិភ័យការងារ

- សហគ្រាសបានចុះបញ្ជីគិតត្រឹមឆ្នាំ២០២២ មានចំនួន ២០ ៩៤៨សហគ្រាស សមាជិកចំនួន ២ ៥៨៤ ៧០៦នាក់ ស្រីចំនួន ១ ៦៤៦ ៣៩៧នាក់។ នៅក្នុងឆ្នាំ២០២២ មានសហគ្រាសចុះបញ្ជីសរុប ៣ ១០៥សហគ្រាស មានកម្មករនិយោជិត ២៧៥ ៧៤៨នាក់ ក្នុងនោះសហគ្រាសបានបង់ភាគទានមាន ១១ ៦២៥សហគ្រាស ដែលមានសមាជិក ១ ៣៨៨ ៦២៣នាក់ និងទទួលបានភាគទានសរុប ១៣៧,៧១ប៊ីលានរៀល



អាសយដ្ឋាន អាគារទីស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ , ០២៣ ៩៩ ៥២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

- បានផ្ដល់តាវកាលិកហានិភ័យការងារសរុបចំនួន ១៣ ៧៤២ឯកសារ មានជនរងគ្រោះចំនួន ៩ ០១៣នាក់ ស្រីចំនួន ៤ ៥២១នាក់ ដែលមានអ្នកចូលប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាលចំនួន ១៣ ៥០៦ករណី ស្រីចំនួន ៧ ១៦៦ករណី និងបានផ្ដល់សេវាស្ដារនីតិសម្បទាសរុបចំនួន ១៥៧ដង.នាក់ ស្រីចំនួន ៥៩ដង.នាក់ សរុបការចំណាយអស់ ២២,៣០ប៊ីលានរៀល
- ចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ផ្នែកហានិភ័យការងារបានចំនួន ៣២៧មូលដ្ឋានសុខាភិបាល ក្នុងនោះមន្ទីរពេទ្យថ្នាក់ជាតិ ០៦ មន្ទីរពេទ្យបង្អែក ១២២ មណ្ឌលសុខភាព ១២៣ និងមន្ទីរពេទ្យឯកជន ៧៦។

❖ **ផ្នែកថែទាំសុខភាព**

- សហគ្រាសបានចុះបញ្ជីគិតត្រឹមឆ្នាំ២០២២ មានចំនួន ១៧ ៨២១សហគ្រាស សមាជិកចំនួន ២ ៥៨៤ ៧០៦នាក់ ស្រីចំនួន ១ ៦៤៦ ៣៩៧នាក់។ ក្នុងឆ្នាំ២០២២ មានសហគ្រាសចុះបញ្ជីសរុប ៣ ១០៥សហគ្រាស មានកម្មករនិយោជិត ២៧៨ ៧៤៨នាក់ ក្នុងនោះសហគ្រាសបានបង់ភាគទានសរុប ១១ ៦២៣សហគ្រាស ដែលមានសមាជិក ១ ៣៨៦ ៨៧៩នាក់ និងទទួលបានភាគទានសរុប ៤៤៦,២៥ប៊ីលានរៀល
- បានផ្ដល់តាវកាលិកថែទាំសុខភាពសរុបចំនួន ៦៤ ៩១២ឯកសារ មានជនរងគ្រោះចំនួន ៦៤ ០៩៩នាក់ ស្រីចំនួន ៦០ ៣៦១នាក់ ដែលមានអ្នកចូលប្រើប្រាស់សេវាចំនួន ២ ៦៦២ ៣៣៥ករណី ស្រីចំនួន ២ ០៥៤ ៦៨៨ករណី និងបានផ្ដល់សេវាស្ដារនីតិសម្បទាសរុបចំនួន ១៤ដង.នាក់ ស្រីចំនួន ១០ដង.នាក់ សរុបការចំណាយអស់ ២៦០,១០ប៊ីលានរៀល
- ចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ផ្នែកថែទាំសុខភាពបានចំនួន ១ ៥០១ ដែលក្នុងនោះមន្ទីរពេទ្យថ្នាក់ជាតិ ០៦ មន្ទីរពេទ្យបង្អែក ១២៣ មណ្ឌលសុខភាព ១ ២៤២ និងមន្ទីរពេទ្យឯកជន ១៣០។

❖ **ផ្នែកប្រាក់សោធនៈ**

សហគ្រាសបានចុះបញ្ជីគិតត្រឹមឆ្នាំ២០២២ មានចំនួន ១៤ ៣៥២សហគ្រាស សមាជិកចំនួន ២ ៥៨៤ ៧០៦នាក់ ស្រីចំនួន ១ ៦៤៦ ៣៩៧នាក់ ក្នុងនោះ ផ្នែកប្រាក់សោធនដោយស្ម័គ្រចិត្តមានសមាជិកសរុបចំនួន ២ ៧០៦នាក់ ស្រីចំនួន ៩៩២នាក់ និងទទួលបានភាគទានសរុប ១១១,៣២ប៊ីលានរៀល។

**២- ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

❖ **ផ្នែកហានិភ័យការងារ**

- សម្រាប់មន្ត្រីសាធារណៈបានចុះបញ្ជីសរុបគិតត្រឹមឆ្នាំ២០២២ ចំនួន ៣៥ស្ថាប័ន មានសមាជិកសរុបចំនួន ២៥៧ ៦៤៤នាក់ ស្រីចំនួន ១០៧ ៦៥០នាក់ និងទទួលបានភាគទានសរុបក្នុងឆ្នាំ២០២២ ប្រមាណជា ៤,៦៩ប៊ីលានរៀល

- បានផ្តល់តាវកាលិកហានិភ័យការងារសរុបចំនួន ៧១ឯកសារ មានជនរងគ្រោះចំនួន ៧០នាក់ ស្រីចំនួន ១៨នាក់ ដែលមានអ្នកចូលប្រើប្រាស់សេវាចំនួន ៦៣ករណី ស្រីចំនួន ២៥ករណី និងបានផ្តល់សេវាស្តារនីតិសម្បទាសរុបចំនួន ៩ដង.នាក់ ស្រីចំនួន ២ដង.នាក់ សរុបការចំណាយអស់ ០,៣២ប៊ីលានរៀល។

❖ **ផ្នែកថែទាំសុខភាព**

- បានចុះបញ្ជីគិតត្រឹមឆ្នាំ២០២២ សរុបចំនួន ៣៩ស្ថាប័ន មានសមាជិកសរុបចំនួន ៨៣៩ ២៤៣នាក់ ស្រីចំនួន ១៣១ ២៩១នាក់ និងទទួលបានភាគទានសរុបក្នុងឆ្នាំ២០២២ ប្រមាណ ជា ៤០,៥២ប៊ីលានរៀល
- បានផ្តល់តាវកាលិកថែទាំសុខភាពសរុបចំនួន ១១០ឯកសារ មានជនរងគ្រោះចំនួន ១០១នាក់ ស្រីចំនួន ៣៣នាក់ ដែលមានអ្នកចូលប្រើប្រាស់សេវាចំនួន ៣៣៧ ៧០៥ ករណី ស្រីចំនួន ១៩០ ៦៧៧ករណី និងបានផ្តល់សេវាស្តារនីតិសម្បទាសរុបចំនួន ១៥ដង.នាក់ ស្រីចំនួន ៤ដង.នាក់ សរុបការចំណាយអស់ ៦៣,១៨ប៊ីលានរៀល។

**៣- ការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនឆ្នាំ២០២២៖**

- សហគ្រាសបានចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធចំនួន ៩៤៣សហគ្រាស មានសមាជិកចំនួន ៩៦ ២៥៩នាក់ ស្រីចំនួន ២០ ៨២២នាក់
- ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធមានម្តាយសរុបចំនួន ៥៥ ៧៧០នាក់ កូនសរុបចំនួន ៥៦ ១៧៣នាក់ និងចំណាយថវិកាសរុប ២២,៤៧ប៊ីលានរៀល។

**៤- ការពង្រឹងការងារគាំទ្រ**

- បានបន្តរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គមអាណត្តិទី១ ឆ្នាំ២០២២ របស់ខ្លួនបានចំនួន ០៦លើក
- បានបន្តរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. ចំនួន ២៩លើក។ គ្រូពេទ្យផ្លូវការនៃ ប.ស.ស. បានបន្តរៀបចំកិច្ចប្រជុំចំនួន ៣៦លើក ដើម្បីវាយតម្លៃតាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ជូនជនរងគ្រោះចំនួន ១ ០០៥នាក់ ស្រីចំនួន ៣៨៥នាក់
- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតបានបន្តរៀបចំកិច្ចប្រជុំផ្ទៃក្នុងចំនួន ០១លើក និងបានចុះអង្កេតករណីកម្មករនិយោជិតមានគ្រោះថ្នាក់ចរាចរណ៍ និងជួយសង្គ្រោះបន្ទាន់បានចំនួន ១៣ករណី ក្នុងនោះមានកម្មករនិយោជិតទទួលរងគ្រោះថ្នាក់សរុបចំនួន ៣៨០នាក់ ស្រីចំនួន ៣៥៥នាក់
- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតបានចុះអង្កេតករណីកម្មករនិយោជិតសន្លប់ សម្របសម្រួលចាត់វិធានការកែលម្អ និង

ជួយសង្គ្រោះបន្ទាន់បានចំនួន ០៨រោងចក្រ និងមានកម្មករនិយោជិតសន្លប់សរុបចំនួន ២៦៦នាក់ ស្រីចំនួន ២២១នាក់

- ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមបានបន្តរៀបចំធ្វើអត្តសញ្ញាណប័ណ្ណថ្មី ទទួលពាក្យបណ្តឹងបាត់អត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណខូចគុណភាព អត្តសញ្ញាណប័ណ្ណកែតម្រូវ និងបន្តសុពលភាពជូនដល់សមាជិក ប.ស.ស. តាមរាជធានី ខេត្ត បានសរុបចំនួន ៣ ២០៦នាក់ ស្រីចំនួន ១ ៦៩៥នាក់ ដែលមានសមាជិកថតថ្មីសរុប ២៨០នាក់ ស្រីចំនួន ១៨៩នាក់ ទទួលពាក្យបណ្តឹងបាត់អត្តសញ្ញាណប័ណ្ណចំនួន ៧៧៨នាក់ ស្រីចំនួន ៩២៩នាក់ អត្តសញ្ញាណប័ណ្ណខូចគុណភាពចំនួន ២៩៧នាក់ ស្រីចំនួន ៥០នាក់ អត្តសញ្ញាណប័ណ្ណកែតម្រូវចំនួន ៧៩នាក់ ស្រីចំនួន ៩១នាក់ និងបន្តសុពលភាពចំនួន ១ ៧៧៧នាក់ ស្រីចំនួន ៩៩៦នាក់
- បានពង្រឹងកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍន៍/សមាគមអន្តរជាតិទាំងក្នុង និងក្រៅប្រទេស
- បានបន្តការពង្រឹងការងារផ្សព្វផ្សាយស្តីពី ការអនុវត្តរបបសន្តិសុខសង្គម ការផ្សព្វផ្សាយពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ការផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គមជូនដល់កម្មករនិយោជិត ការផ្សព្វផ្សាយអប់រំច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត និងអ្នកបើកបរនៅក្នុងឆ្នាំ២០២២ សម្រេចបាន ៤ ៣៩៧លើក មានអ្នកចូលរួមសរុបចំនួន ១ ១៦២ ០៩៦នាក់ ស្រីចំនួន ៧៧៩ ៦១៦នាក់
- បានបន្តការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមតាមរយៈ Facebook Page បេឡាជាតិសន្តិសុខសង្គមបានចំនួន ៩២៣ព័ត៌មាន តាមរយៈគេហទំព័រ www.nssf.gov.kh បានចំនួន ៣៥១ព័ត៌មាន តាមរយៈ YouTube និង Telegram Channel (បេឡាជាតិសន្តិសុខសង្គម) បានចំនួន ២៩២ព័ត៌មាន ការផ្សាយផ្ទាល់ (Live) លើ Facebook Page បានចំនួន ០១ព័ត៌មាន និងការធ្វើព្រឹត្តិបត្រព័ត៌មាន ប.ស.ស. បានចំនួន ០២ព្រឹត្តិបត្រ។

## ខ. ទិសដៅអនុវត្តបន្តឆ្នាំ២០២៣

បើទោះបីជា ប.ស.ស. សម្រេចបានសមិទ្ធផលគួរជាទីគាប់ចិត្តនៅក្នុងឆ្នាំ២០២២ ក៏ដោយក៏ ប.ស.ស. នៅតែបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្តទៀត ដើម្បីសម្រេចឱ្យបានភារកិច្ចថ្មីៗ ប្រកបដោយការយកចិត្តទុកដាក់ និងទំនួលខុសត្រូវខ្ពស់ ដូចខាងក្រោមបន្ថែមទៀត៖

- បន្តយកចិត្តទុកដាក់ក្នុងការចូលរួមយ៉ាងសកម្ម ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រព័ន្ធសន្តិសុខសង្គម និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដើម្បី "កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព" បន្តអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

- បន្តអនុវត្តតាមអនុសាសន៍របស់ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនបន្តសិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការផ្នែកនិកម្មភាពការងារបន្តទៀត ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍/សមាគមអន្តរជាតិទាំងក្នុង និងក្រៅប្រទេស
- បន្តពង្រឹងការងារគាំទ្ររបស់ ប.ស.ស. ដោយផ្តោតសំខាន់ទៅលើការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗ ឱ្យស្របទៅតាមការវិវត្តសេដ្ឋកិច្ចសង្គមជាតិ និងតាមបទដ្ឋានអន្តរជាតិតាមបណ្តាប្រទេសនានា ដែលជាសមាជិកសមាគមសន្តិសុខសង្គមអាស៊ាន តាមរយៈក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម ការងារគ្រប់គ្រងការបណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ការពង្រឹងការងារសវនកម្មផ្ទៃក្នុង ការសម្របសម្រួលដោះស្រាយវិវាទ ឬបណ្តឹងរបស់បេឡាជាតិសន្តិសុខសង្គម ដែលជាចំណុចត្រូវតែអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងយកចិត្តទុកដាក់ជាទីបំផុតដើម្បីទទួលបានលទ្ធផលជាវិជ្ជមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣